# បទអត្ថាធិប្បាយអំពីការវះកាត់ថនិកសត្វ

**ការណែនាំដំបូង**

វីដេអូនេះនឹងបង្ហាញលោកអ្នកអំពីរបៀបធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយវះកាត់សាកសពថនិកសត្វ និងរបៀបប្រមូលសំណាកសំខាន់ៗដែលអាចជួយដល់ការតាមដានត្រួតពិនិត្យ និងស្វែងរកជម្ងឺ ។

**ការត្រៀមលក្ខណៈ:**

ដើម្បីអាចយកសំណាកបានពេញលេញ អ្នកចាំបាច់ត្រូវត្រៀមលក្ខណៈដូចខាងក្រោម៖

សម្លៀកបំពាក់ និងឧបករណ៍ការពារខ្លួន (ឬ PPE) រួមទាំងឧបករណ៍ដកដង្ហើមប្រភេទ N95 វ៉ែនតា ឬក្បាំងការពារភ្នែក ស្រោមដៃ ស្បែកជើងកវែងកៅស៊ូ និងសម្លៀកបំពាក់ការពារដូចជា ខោជាប់អាវ និង/ឬអាវអៀមជាដើម ។

ត្រូវមានទម្រង់សម្រាប់កត់ត្រាការសង្កេតឃើញរបស់អ្នកឲ្យបានត្រឹមត្រូវ

ត្រូវមានកាម៉េរាសម្រាប់ថតរូបភាពទុក

មានបន្ទាត់ ឬម៉ែត្រសំពត់សម្រាប់វាស់វែងគំហើញផ្សេងៗ និងកត់ត្រារង្វាស់រង្វាល់ទុកលើគ្រប់រូបថតទាំងអស់

ត្រូវមានហ្វឺតលុបមិនជ្រះ និងខ្មៅដាំសម្រាប់សរសេរស្លាក

ឧបករណ៍សម្រាប់ដាក់សំណាកដែលប្រមូលបានដូចជា ទឹកហ្វ័រម៉ាលីនប្រភេទ១០% បំពង់កែវទទេរ បំពង់ RNA later និង/ឬ ឧបករណ៍ផ្ទុកមេរោគ និងសំឡីត្បារដែលគ្មានមេរោគ

ប្រដាប់ប្រដារមួយចំនួនដូចជា ដង្កៀបស្ដាបុាំង ដំបៀត កន្ត្រៃ រណារ កាំបិតជាដើម ។

មុនពេលអ្នកចាប់ផ្ដើម ត្រូវប្រាកដថាអ្នកបានប្រមូលព័ត៌មានអំពីសាកសពសត្វដែលពាក់ព័ន្ធទាំងអស់ រួមមានដូចជា៖ ទីតាំងដែលប្រមូល ស្ថានភាពបរិស្ថាននៅជុំវិញ និងលក្ខណៈនៃការស្លាប់ ហើយអ្នកត្រូវប្រាកដថាបានកត់ត្រាព័ត៌មាននេះនៅលើទម្រង់សមស្របរួចរាល់អស់ហើយ ។

បន្ទាប់មក រៀបចំក្រុមការងាររបស់អ្នក។ ប្រសិនបើមានមនុស្ស 2 នាក់ ត្រូវកំណត់មនុស្សម្នាក់ថាជា អ្នកដែលត្រូវប្រឡូកប្រឡាក់ដោយផ្ទាល់ ឬហៅថា "អ្នកកខ្វក់" និងម្នាក់ទៀតជា "អ្នកស្អាត" ។ សមាជិកក្រុមដែលជា "អ្នកកខ្វក់" គឺជាអ្នកដែលត្រូវប៉ះពាល់ កាត់ និងយកគំរូពីសាកសពសត្វ ។ ឯសមាជិកក្រុមដែលជា "អ្នកស្អាត" មិនត្រូវប៉ពាល់សត្វ ឬឧបករណ៍ សម្ភារៈដែល "កខ្វក់" ណាមួយឡើយ ។ គេជាអ្នកដែលត្រូវប៉ះពាល់ ឬប្រើប្រាស់តែឧបករណ៍ដែលនៅស្អាត កត់ត្រាការសង្កេត សរសេរស្លាក និងថតរូបប៉ុណ្ណោះ ។ ការរៀបចំបែបនេះនឹងជួយទប់ស្កាត់កុំឲ្យប៉ះពាល់ជីវសាស្ត្រ (biocontainment) និងកាត់បន្ថយការចម្លងរោគក្នុងអំឡុងពេលវះកាត់ពិនិត្យសាកសព ។

ជាចុងក្រោយ មុននឹងយកសំណាក ត្រូវសរសេរស្លាកលើប្រដាប់ដាក់សំណាកទាំងអស់នូវព័ត៌មានអំពីអត្តសញ្ញាណឲ្យបានត្រឹមត្រូវ ។ ប្រដាប់ដាក់សំណាកទាំងអស់ យ៉ាងហោចណាស់ ត្រូវតែមានលេខអត្តសញ្ញាណសត្វ ឈ្មោះសត្វ ប្រភេទសំណាក និងកាលបរិច្ឆេទ។

វះកាត់ពិនិត្យសាកសព

ជាទូទៅ៖

នៅក្នុងអំឡុងពេលវះកាត់នោះ ប្រសិនបើអ្នកឃើញអ្វីមួយដែលអ្នកគិតថាមិនប្រក្រតី ឬប្រសិនបើអ្នកមិនច្បាស់ថាតើវាធម្មតាឬអត់នោះ សូមថតរូប និងយកសំណាកនៃអ្វីដែលអ្នកគិតថាមិនប្រក្រតី និងជាលិកាធម្មតាដែលនៅជាប់គ្នា ។ រៀបរាប់អំពីអ្វីដែលអ្នកបានឃើញលើទម្រង់វះកាត់ពិនិត្យសាកសព ។

គប្បីថតរូបឲ្យជាប់ទាំងស្លាកកត់ត្រាកាលបរិច្ឆេទ និងលេខអត្តសញ្ញាណសត្វ និងផ្នែកនៃម៉ែត្រសំពត់ ឬបន្ទាត់ដើម្បីឲ្យដឹងអំពីទំហំរបស់វា ។

សូមរៀបរាប់អំពីអ្វីដែលអ្នកសង្កេតឃើញ ដោយប្រើពាក្យសាមញ្ញៗ និងដោយបញ្ជាក់អំពីពណ៌ ទំហំ (ដូចជាបណ្តោយ ទទឹង កម្រាស់) និងត្រូវមានលក្ខណៈស៊ីសង្វាក់គ្នា ។ សូមចងចាំថាការរៀបរាប់នេះវាគ្រាន់តែជាការពិពណ៌នារបស់យើងប៉ុណ្ណោះ មិនមែនជាការបកស្រាយពន្យល់ឡើយ ។ ការបកស្រាយពន្យល់ត្រូវផ្អែកលើព័ត៌មាន និងរូបថតទាំងអស់ដែលត្រូវបានប្រមូលផ្តុំក្នុងអំឡុងពេលវះកាត់ពិនិត្យសាកសព ។ ពេទ្យសត្វ ឬគ្រូពេទ្យជំនាញផ្នែកជម្ងឺសត្វដែលជាដៃគូរបស់អ្នកអាចជួយក្នុងការបកស្រាយពន្យល់អំពីការរកឃើញរបស់អ្នកបាន ។

សូមចំណាំថា នៅពេលប្រមូលយកសំណាកដាក់ទៅក្នុងដបហ្វ័រម៉ាលីន សូមព្យាយាមកាត់សំណាកនោះឲ្យតូច ដើម្បីកុំឱ្យវាក្រាស់ជាង 1 សង់ទីម៉ែត្រ ហើយដាក់វាទៅក្នុងទឹកហ្វ័រម៉ាលីនក្នុងសមាមាត្រ 10: 1 នៃជាលិកា។ បើសិនជាពុំបានធ្វើដូច្នេះ នោះវានឹងរំខានដល់ការជួសជុលជាលិកាត្រឹមត្រូវ ហើយវានឹងប៉ះពាល់ដល់ការត្រួតពិនិត្យជាលិកា (histologic examination) ។

ការត្រួតពិនិត្យពីខាងក្រៅ៖

បើអាចធ្វើបាន ត្រូវថ្លឹងទម្ងន់សាកសព ។

វាស់វែងសាកសព ទាំងប្រវែងដងខ្លួន និងកន្ទុយ

ពិនិត្យមើល និងកត់ត្រាភេទរបស់សត្វនោះ ស្ថានភាពក្រោយសត្វងាប់ ស្ថានភាពសាកសព និងថ្នាក់នៃអាយុសត្វនៅលើទម្រង់វះកាត់ពិនិត្យសាកសព ។

ត្រួតពិនិត្យមើលសាកសពសត្វពីខាងក្រៅចាប់ពីក្បាលដល់ចុងក្រចក ។ គត់ត្រាអំពីស្នាមរបួស បាក់ ដំបៅ ឬភាពមិនប្រក្រតីនានាដែលអាចមើលឃើញពីខាងក្រៅ ។ បើឃើញមានអេកតូប៉ារ៉ាសិត ឬប៉ារ៉ាសិតខាងក្រៅ សូមយកវាដាក់ទៅក្នុងបំពង់ត្រាំអាល់កុល ៧០% ។

ថតរូបសាកសព និងភាពមិនប្រក្រតីនានាដែលអ្នកបានកត់សម្គាល់។

យកសំឡីត្បារយកសំណាកតាមបំពង់ករ និងគូទ រួចដាក់វាទៅក្នុងប្រដាប់ផ្ទុកសំណាកមេរោគ និង/ឬ បំពង់ RNA ។

ចំពោះថនិកសត្វធំៗគួរដាក់សាកសពឲ្យផ្អៀងទៅចំហៀង ចំណែកថនិកសត្វតូចៗអាចដាក់ផ្ងារ ឬផ្អៀងក៏បាន ។ បើអាចធ្វើទៅបាន ចូរដាក់សត្វសត្វទំពារអៀងឲ្យផ្អៀងទៅខាងឆ្វេង ដោយសារតែក្រពះទី១របស់វាស្ថិតនៅផ្នែកខាងឆ្វេង ។

បើសត្វផ្អៀងចំហៀង ត្រូវលើកជើងមុខដែលនៅខាងលើ រួចព្រលះស្បែក កាត់យកជាលិកាក្រោមស្បែក និងសាច់ដុំកៀនក្រលៀនឲ្យដល់ឆ្អឹងសន្លាក់ស្លាបប្រជៀវ ។ បើកចំហរត្រង់សន្លាក់ ពន្លាត់ឆ្អឹង រួចត្រួតពិនិត្យមើលសន្លាក់ស្មារ ។ ធ្វើដូចគ្នាដែរចំពោះជើងក្រោយដែលនៅខាងលើ ដូចអ្វីដែលបានធ្វើចំពោះជើងមុខ ដោយកាត់ពីក្រលៀនខាងក្រោយរហូតដល់សន្លាក់ត្រគៀក ។ បើកចំហរត្រង់សន្លាក់ ពន្លាត់ឆ្អឹង រួចត្រួតពិនិត្យមើលសន្លាក់ត្រគៀកក្រោយ ។ វះបន្ថែមឲ្យដល់កន្ទុយចំពាក់កណ្ដាល ។ ពន្លះស្បែកចេញពីសាច់ដោយធ្វើយ៉ាងណាមិនឲ្យមុតចូលទៅក្នុងគ្រឿងក្នុងសត្វឡើយ ។

បើសត្វងាប់ផ្ងារពោះ អ្នកត្រូវហែកជើងទាំងពីរទាំងមុខ ទាំងក្រោយ បើកចំហរឲ្យដល់សន្លាក់ដូចរៀបរាប់ខាងលើដែរ បន្ទាប់មកវះចំកណ្ដាលដើម្បីបកស្បែក ។ ត្រូវកត់ត្រាអំពីបរិមាណខ្លាញ់នៅក្រោមស្បែកនៅពេលកាត់ពីក្រោមស្បែករហូតដល់សាច់ដុំ ។

វះតាមខ្សែបណ្ដោយកណ្ដាលពីក្រោមគល់កឡើងរហូតដល់ចង្ការ ។

យកបំណែកស្បែក និងសាច់មួយដុំដាក់ត្រាំក្នុងទឹកហ្វ័រម៉ាលីន ។ បើសិនជាចាប់អារម្មណ៍ចង់ធ្វើតេស្តសហ្សេនីទិកបន្ថែមទៀត សូមដាក់ត្រាំសំណាកមួយដុំទៀតក្នុងកែវអេតាណុល ៧០% ។

បើកចំហរត្រង់សន្លាក់ ពន្លាត់ឆ្អឹង រួចត្រួតពិនិត្យមើលសន្លាក់ជង្គង់ ។ វះសាច់ដុំពីកន្ទុយដល់ឆ្អឹងភ្លៅ ឆ្អឹងលើក្បាលជង្គង់ដើម្បីរកមើលសរសៃពួរ ។ ត្រាំវាក្នុងទឹកហ្វ័រម៉ាលីន ។ បន្ទាប់មកត្រូវយកសំណាកពីខួរឆ្អឹង និងសរសៃពួរ ។ វែបំបាក់ឆ្អឹងពីរកន្លែង ត្រូវតម្រង់កន្លែងវាយបំបាក់នោះឲ្យត្រូវគ្នាទើបអាចបំបែកឆ្អឹងបាន ។ ដាក់សំណាកត្រាំក្នុងទឹកហ្វ័រម៉ាលីន ។

**ចំណុចត្រួតពិនិត្យ ទី១៖**

មកដល់ចំណុចនេះ អ្នកគួរមានដូចខាងក្រោម៖

- រូបថតសាកសព និងចំណុចខុសប្រក្រតីនានាដែលអ្នកបានឃើញ
- កំណត់ត្រានានាដែលរួមមានទាំងប្រវែងដងខ្លួន និងទម្ងន់សត្វ
- សំឡីយកសំណាកតាមបំពង់ករ និងគូទ
- សំណាកស្បែក សាច់ដុំ សរសៃពួរ និងខួរឆ្អឹង

ពេលនេះអ្នកអាចវះបើកពិនិត្យមើលគ្រឿងក្នុងសត្វបានហើយ ។
បើសត្វផ្អៀងទៅចំហៀង សូមវះបើកពនិត្យមើលគ្រឿងក្នុងសត្វរាងជាអក្សរ L ។ ដំបូងកាត់ពីឆ្អឹងប្រអប់ទ្រូង តាមបណ្ដោយគែមខាងក្រោយនៃឆ្អឹងជំនីរឆ្ពោះទៅឆ្អឹងខ្នង។ បន្ទាប់មកកាត់តាមខ្សែបន្ទាត់កណ្ដាលពីឆ្អឹងប្រអប់ទ្រូង ឆ្ពោះទៅកន្ទុយទៅឆ្អឹងអាងត្រគាក។ បើកប្រហោងពោះឲ្យឃើញដល់ជញ្ជាំងពោះ។ ប្រសិនបើសត្វងាប់ផ្ងារ ត្រូវវះកាត់រាងជាអក្សរ T ដើម្បីបើកគ្រឿងក្នុងក្នុងសាកសពសត្វ ។ ដំបូងកាត់ពីផ្នែកម្ខាងនៃសាកសពសត្វទៅម្ខាងទៀតតាមគែមខាងក្រោយនៃឆ្អឹងជំនី ។ បន្ទាប់មកកាត់តាមខ្សែបន្ទាត់កណ្ដាលពីឆ្អឹងប្រអប់ទ្រូង ទៅឆ្អឹងអាងត្រគាក ។ ព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីចៀសវាងវះជ្រៅពេកដែលធ្វើឲ្យប៉ះពាល់ដល់ពោះវៀន ឬប៉ះសរីរាង្គណាមួយ មុនត្រូវយកសំណាក ។

សូមកត់ត្រាស្រទាប់ខ្លាញ់ និងថតរូបគ្រឿងក្នុងទាំងមូលសិនមុននឹងបន្តការងារទៀត ។

បើមានទឹករំអិលអ្វី សូមកត់សំគាលពណ៌របស់វា ភាពស៊ីសង្វាក់(ភាពប្រក្រតី) និងវាល់ ឬព្យាយាមប៉ាន់ស្មានបរិមាណរបស់វា ។ ប្រសិនជាទឹករំអិលនោះមានច្រើនលើសពីបរិមាណដ៏តិចតួចបំផុតនោះ មានន័យថាវាខុសប្រក្រតីហើយ ។ សូមថតរូប និងយកសំណាកដាក់ក្នុងបំពង់កែវទទេរ ។

កត់ត្រាទំហំថ្លើម ។ ធម្មតាថ្លើមមិនធំហួសចុងកន្ទុយនៃឆ្អឹងជំនីទ្បើយ ។

ពេលនេះដល់ពេលរកមើលក្នុងសន្ទះទ្រូងម្តង ។ វាជាស្រទាប់សាច់ដុំដែលចែកថតទ្រូងពីផ្ទៃពោះសត្វ ។ ទះវាថ្នមៗដើម្បីវាយតម្លៃសម្ពាធក្នុងប្រអប់ទ្រូង។ បើសិនជាធម្មតា វានឹងប៉ោងចេញមកក្រៅឆ្ពោះមកអ្នក ។ សូមពិនិត្យមើលក្នុងប្រអប់ទ្រូងនោះ ។ បើមានទឹករំអិល សូមកត់សំគាលពណ៌របស់វា ភាពស៊ីសង្វាក់(ភាពប្រក្រតី) និងប៉ាន់ស្មានបរិមាណវា ។ យកសំណាកដោយប្រើប្រាស់សំឡីត្បារ ឬសឺរ៉ាំងបូម ។

ដើម្បីបន្តវះបើកមើលក្នុងប្រអប់ទ្រូង សូមវះកាត់សន្ទះទ្រូងពីដងខ្លួនម្ខាង ទៅម្ខាងទៀតតាមគែមខាងក្រោយនៃឆ្អឹងជំនី។

ដើម្បីកាត់ឆ្អឹងជំនី បើសត្វដេកផ្អៀង សូមកាត់ឆ្អឹងជំនីស្របទៅនឹងឆ្អឹងខ្នងតាមបន្ទាត់កណ្តាល ។ បើសត្វដេកផ្ងារ សូមកាត់ឆ្អឹងជំនីទាំងសង្ខាងតែម្តង ។ កាត់យកគ្រោងឆ្អឹងជំនីចេញ ។

រកមើលបេះដូង រួចកាត់បើថង់ជុំវិញបេះដូងឲ្យចំហរដោយប្រុងប្រយ័ត្នបំផុតដើម្បីងាយស្រួលមើល ។

មុននឹងប៉ះពាល់អ្វីបន្តទៀត សូមថតរូបផ្ទៃទ្រូង និងពោះឲ្យឃើញសរីរាង្គនានានៅត្រង់កន្លែងដើមរបស់វាដូចពីដើមដំបូងដែលយើងបានឃើញ ។ សូមកត់សំគាល់ចំណុចខុសប្រក្រតីនានា ។

មុននឹងប៉ះពាល់ជាលិកាណាមួយ សូមយកសំណាកសម្រាប់ធ្វើរោគវិនិច្ឆ័យតាមម៉ូលេគុល ដូចជាសំណាកជាលិកាដាក់ក្នុងបំពង់ VTM ឬ RNA ឬសំឡីសម្រាប់ត្បារយកមេរោគ ឬដុំពកសម្រាប់បណ្តុះមេរោគពពួកផ្សិតជាដើម ។

**ចំណុចត្រួតពិនិត្យ ទី២៖**
មកដល់ចំណុចនេះ អ្នកគួរមានដូចខាងក្រោម៖
រូបថតនៃប្រអប់ទ្រូង និងស្រទាប់នានាពីផ្ទៃពោះដល់គូទសត្វ
បានយកសំណាកសម្រាប់ធ្វើរោគវិនិច្ឆ័យតាមម៉ូលេគុល ឬការបណ្តុះមេរោគ

ពេលនេះដល់ពេលត្រូវត្រួតពិនិត្យលម្អិតលើសរីរាង្គ ឬប្រព័ន្ធសរីរាង្គនីមួយៗបន្ថែមទៀត ។ ដោយចាប់ផ្តើមពីប្រអប់ទ្រូង សូមត្រួតពិនិត្យឲ្យបានល្អិតល្អន់ និងយកសំណាកពីក្រពេញទីរ៉ូអ៊ីត ។ ក្រពេញទីរ៉ូអ៊ីតជាសរីរាង្គតូចៗមានពណ៌ពីពណ៌ផ្កាឈូកទៅក្រហម ស្ថិតនៅសង្ខាងកញ្ចឹងកខាងក្រោមរង្វង់ឆ្អឹងខ្ចីក្រាស់ ជិតផ្នែកខាងលើនៃបំពង់ខ្យល់ ។ សូមកត់ត្រាអំពីភាពមិនប្រក្រតីនានា រួចដាក់ក្រពេញទីរ៉ូអ៊ីតត្រាំក្នុងទឹកហ្វ័រម៉ាលីន ។

ពេលនេះដល់ពេលវះកាត់យក សំណុំគ្រឿងក្នុង ដែលរួមមានទាំងអណ្តាត បំពង់អាហារ បំពង់ខ្យល់ បេះដូង និងសួត ។ សូមវះអណ្តាតពីចំហៀងបន្តិចដើម្បីអាចរុញអណ្តាតឡើងពីខាងក្រោមថ្គាមមកលើ ។ រួចហើយទាញយកអណ្តាតនោះ

ចេញមកបណ្តើរកាត់កោសិកានានាដែលជាប់ជាមួយបណ្តើរដើម្បីយកទាំងបំពង់ខ្យល់ និងបំពង់អាហារចេញមកតាមគល់កជាមួយគ្នាតែម្តង ។ រួចបន្តព្រលះរហូតសន្ទះទ្រូង ។ សូមទាញយកគ្រឿងក្នុងទាំងអស់នោះចេញពីប្រអប់ទ្រូងដោយកាត់ផ្តាច់ត្រឹមបំពង់អាហារដែលស្ថិតស្មើនឹងសន្ទះទ្រូង ។

សូមពិនិត្យមើលសភាពខាងក្រៅនេះកោសិកាទាំងអស់នោះដោយកត់សំគាល់រាល់ភាពខុសប្រក្រតីនានា ។ សូមយកសំណាកដោយកាត់យកអណ្តាតមួយផ្នែកដែលមានកម្រាស់ពេញដាក់ត្រាំក្នុងទឹកហ្វ័រម៉ាលីន ។ ដើម្បីពិនិត្យផ្នែកខាងក្នុងនៃបំពង់ខ្យល់ និងបំពង់អាហារ សូមវះបើកតាមបណ្តោយបំពង់ខ្យល់ រួចកត់សំគាល់មើលទឹករំអិល និងថតរូបទុក ។ សូមវះបើកបំពង់អាហារតាមរបៀបស្រដៀងគ្នានេះដែរ ។ សូមយកកាត់យកសំណាកពីបំពង់ខ្យល់ និងបំពង់អាហាររួចដាក់ត្រាំក្នុងទឹកហ្វ័ម៉ាលីនជាមួយគ្នាតែម្តង ។

កាត់បេះដូងចេញ ។ សូមចងចាំថាបេះដូងមានថតខាងស្តាំ ខាងឆ្វេង និងកណ្តាល ។ ផ្នែកខាងស្តាំតូច និងស្តើងជាងផ្នែកខាងឆ្វេង ។ ទាំងសង្ខាងមានផ្នែកខាងលើ ហៅថាថតលើ ឬ Atrium និងផ្នែកខាងក្រោម ហៅថាថតក្រោម ឬ Ventricle ។ វះបើកបេះដូងទាំងស្តាំ និងឆ្វេង ។ សូមយកសំណាកតាមបណ្តោយពីកំពូលដល់បាតនៃបេះដូង ដែលរួមមានទាំង Atrium និង Ventricle ពីថតបេះដូងស្តាំ និងឆ្វេង ។ ស្រដៀងគ្នាដែរសូមយកសំណាកពីកំពូលទៅបាតពីផ្នែកកណ្តាលនៃបេះដូង រួចដាក់ត្រាំក្នុងទឹកហ្វ័រម៉ាលីន ។

លាតសួតនៅខាងក្រៅ រួចថតរូប ។
បន្ទាប់មកទើបហាន់សួតកាត់ទទឹងក្នុងគម្លាតស្មើៗដើម្បីពិនិត្យមើលកោសិកាវា ។ គេហៅរបៀបកាត់នេះថាជារបៀបកាត់នំប៉័ង ដោយហាន់វាជាបន្ទះៗដូចចំណិតនំប៉័ង ។ សូមកត់សំគាល់អំពីទឹករំអិលដែលហូរចេញមកនៅពេលអ្នកកាត់ម្តងៗ ។ សូមថតយករូបភាពសួតជាចំណិតៗ រួចយកសួតយ៉ាងតិចមួយចំណែកពីចំណិតសួតនីមួយដាក់ទៅក្នុងបំពង់កែវទទេរ និងត្រាំក្នុងទឹកហ្វ័រម៉ាលីន ។ យកសំណាកបន្ថែមទៀត ប្រសិនបើឃើញមានភាពមិនប្រក្រតីនានា ។ សូមកត់សំគាល់ថាតើសំណាកសួតនោះលិច ឬអណ្តែតពេលដាក់ត្រាំនៅក្នុងទឹកហ្វ័រម៉ាលីន ។

**ចំណុចត្រួតពិនិត្យ ទី៣៖**

មកដល់ចំណុចនេះ អ្នកគួរមានដូចខាងក្រោម៖

- រូបថតនៃគ្រឿងក្នុងសត្វទាំងមូលដែលពុំទាន់កាត់
- រូបថត និងការកត់ត្រាអំពីភាពមិនប្រក្រតីនានាដែលបានជួបប្រទះ
- សំណាកដែលប្រមូលយកពីអណ្តាត បំពង់ខ្យល់ បំពង់អាហារ បេះដូង សួត និងកោសិកាដែលខុសប្រក្រតី

ឈានចូលដល់គ្រឿងក្នុងពោះសត្វវិញម្តង សូមរកមើលថ្លើម ។ វាជាសរីរាង្គធំមួយមានពណ៌ក្រហមត្នោត នៅក្រោយសន្ទះទ្រូង ។ សូមកាត់យកថ្លើមចេញ រួចថតរូបវាទាំងមូល ។ ហាន់ថ្លើមដូចជាចំណិតនំប៉័ងដើម្បីពិនិត្យមើលកោសិកា ។ សូមកត់សំគាល់ភាពមិនប្រក្រតីនានា ព្រមទាំងថតរូបកោសិកាដែលត្រូវបានហាន់ជាចំណិតៗ ។ ដាក់សំណាកមួយទៅក្នុងបំពង់កែវទទេរ រួចដាក់២ ទៅ៣ដុំត្រាំក្នុងទឹកហ្វ័រម៉ាលីន ។ បើសង្ស័យថាសត្វងាប់ដោយសារថ្នាំពុល សូមយកថ្លើមមួយចំណែកធំ (ប្រហែល ៥០ក្រាម) ដាក់ទៅក្នុងថង់ផ្លាស្ទីកមួយ ។

ពេលនេះសូមរយកមើលផាលម្តង ។ វាជាសរីរាង្គទ្រវែង ស្តើង ពណ៌ក្រហមក្រម៉ៅស្វាយ នៅក្នុងពោះខាងឆ្វេង ។ សូមកាត់ផាលចេញពីគេ ថតរូប រួចហាន់វាជាចំណិតដូចនំប៉័ង បន្ទាប់មកយកសំណាកដាក់ត្រាំទឹកហ្វ័រម៉ាលីនក្នុងបំពង់ ។

ដើម្បីត្រួតពិនិត្យផ្លូវរំលាយអាហារ ផ្លូវទឹកនោម និងបំពង់បន្តពូជ សូមកាត់យកសំណុំក្រពះពោះវៀនចេញពីសន្ទះទ្រូង រហូតដល់រន្ធគូថ ។ ទុកវាមួយអន្លើរសម្រាប់ធ្វើការត្រួតពិនិត្យបន្តទៀតក្នុងជំហានបន្ទាប់ ។

បន្ទាប់មកសូមរកមើលផ្លូវទឹកនោម ក្រពេញបន្តពូជ និងក្រពេញតម្រងនោម ។ ក្រលៀនមានពណ៌ក្រហមត្នោត រាងដូចគ្រាប់សណ្តែក នៅជិតឆ្អឹងកងខ្នង ។

ក្រពេញតម្រងនោមស្ថិតនៅពីលើក្រលៀនទាំងសង្ខាង ។ សូមថតរូបក្រលៀនដោយមានក្រពេញតម្រងនោមនៅពីលើផងដែរ ។ សូមយកក្រពេញទាំងពីរនេះដាក់ត្រាំក្នុងទឹកហ្វ័រម៉ាលីន ។

សូមកាត់យកក្រលៀនទាំងពីរចេញ ។ ពុះតាមបណ្តោយក្រលៀនចំពាក់កណ្តាល ។ សូមពិនិត្យមើល និងកត់សំគាល់រាល់ភាពមិនប្រក្រតីនានា ។ សូមចំណាំថាក្រលៀននីមួយៗសុទ្ធតែមានស្រោមស្តើងស្រោបពីក្រៅ ។ សូមកត់សំគាល់ពណ៌របស់វា និងបកស្រោមនោះចេញ ។ យកចំណែកដែលមានកម្រាស់ពេញពីក្រលៀននីមួយៗត្រាំក្នុងទឹកហ្វ័រម៉ាលីន និងយកសំណាកតូចៗដាក់ក្នុងបំពង់កែវ ។ ក្នុងករណីសង្ស័យមានថ្នាំពុល សូមច្រកក្រលៀនក្នុងថង់ផ្លាស្ទីក ។

សូមត្រួតពិនិត្យក្រពេញទឹកនោម បំពង់ទឹកនោម និងរន្ធនោម ។ សូមយកសំណាកពីក្រពេញទឹកនោមដាក់ត្រាំក្នុងទឹកហ្វ័រម៉ាលីន ។

សូមត្រួតពិនិត្យបំពង់បន្តពូជ ។ សត្វឈ្មោលមានពងស្វាសពីរ និងក្រពេញភេទ ដូចជាក្រពេញប្រូស្តាត ។ សត្វញីមានបំពង់អូវែពីរ និងស្បូនមួយ ។ សូមថតរូបក្រពេញបន្តពូជ ។ ត្រូវវះបើកស្រោមពងស្វាស រួចកាត់ពងស្វាស និងអូវែចេញពីគ្នាប្រសិនបើវាធំ ។ ត្រាំសំណាកក្រពេញបន្តពូជ ក្រពេញបន្ទាប់បន្សំផ្សេងៗ និងស្បូន ក្នុងទឹកហ្វ័រម៉ាលីន ។

**ចំណុចត្រួតពិនិត្យ ទី៨៖**

មកដល់ចំណុចនេះ អ្នកគួរមានដូចខាងក្រោម៖

- រូបថតនៃថ្លើម ផាល បំពង់ទឹកនោម និងបំពង់បន្តពូជ
- រូបថត និងការកត់ត្រាអំពីភាពមិនប្រក្រតីនានាដែលបានជួបប្រទះ រួមទាំងទឹករំអិលនានាផងដែរ
- សំណាកដែលប្រមូលយកពីថ្លើម ផាល ក្រលៀន តម្រងនោម ក្រពេញតម្រងនោម ក្រពេញបន្តពូជ និងស្បូន

ជំហានបន្ទាប់គឺត្រូវត្រឡប់មកមើលបំពង់អាហារវិញម្តង ដោយលាតបំពង់អាហារនៅនៅលើផ្ទៃស្អាត ។ លាតវាដាក់ឲ្យរាបស្មើ រួចថតរូបទុក ។
វះបើកបំពង់អាហារដោយកាត់តាមបណ្តោយពីដើមបំពង់អាហាររហូតដល់ពោះវៀនតូច ។ សូមចំណាំថា អាស្រ័យទៅតាមប្រភេទសត្វ ក្រពះសត្វអាចមានថតមួយឬច្រើនស្រទាប់ តួយ៉ាងដូចជាសត្វទំពារអៀងជាដើម ។ នៅពេលវះបើករួចហើយ សូមពិនិត្យមើលអាហារដែលនៅក្នុងស្រទាប់ក្រពះនីមួយៗ ។ យកអាហារចេញ រួចពិនិត្យមើលស្រទាប់ខាងក្នុង

ក្រពះ ។ ករណីសង្ស័យមានថ្នាំពុល សូមយកអាហារពីក្នុងក្រពះ ឬពោះកន្សែងពីសត្វទំពារអៀង ប្រកក្នុងថង់ផ្លាស្ទីក។ សូមកាត់យកកន្លែងដែលមានកម្រាស់ពេញពីគ្រប់ស្រទាប់ក្រពះទាំងអស់ ។

ពេលនេះត្រូវវះតាមបណ្តោយពោះវៀនម្តង ។
ដាក់ពោះវៀនដែលវះបើកចំហររួចនៅលើផ្ទៃស្អាតរាបស្មើ រួចថតរូបទុក ។
សូមកត់សំគាល់មើលពីសភាពខាងក្រៅ និងបរិមាណនេះកាកសំណល់ដែលមាន រួចយកលាមកវាទុកក្នុងបំពង់ទទេរ។ បើអ្នកឃើញមានអង់ដូប៉ារ៉ាស៊ីត សូមយកវាទៅដាក់ក្នុងបំពង់អាល់កុល៧០% ។ សូមយកសំណាកនៃពោះវៀនដែលព្រលាត់ ពេញកម្រាស់ កក្រពះជាប់ជាមួយលំពែង ផ្នែកកណ្តាលនៃពោះវៀនធំ ចុងពោះវៀនតូច ដើមពោះវៀនធំ ពោះវៀនធំ និងចុងពោះវៀនធំ ដាក់ត្រាំក្នុងទឹកហ្វ័រម៉ាលីន ។

**ចំណុចត្រួតពិនិត្យ ទី៨៖**

មកដល់ចំណុចនេះ អ្នកគួរមានដូចខាងក្រោម៖

- រូបថតទាំងផ្នែកខាងក្រៅ និងខាងក្នុងនៃបំពង់អាហារ និងអាហារដែលនោះក្នុងនោះ
- រូបថត និងការកត់ត្រាអំពីភាពមិនប្រក្រតីនានាដែលបានជួបប្រទះ
- សំណាកលាមកសត្វ
- សំណាកដែលយកពីក្រពះ កក្រពះជាប់នឹងលំពែង ផ្នែកកណ្តាលនៃពោះវៀនធំ ចុងពោះវៀនតូច ដើមពោះវៀនធំ ពោះវៀនធំ និងចុងពោះវៀនធំ

បន្ទាប់មកត្រូវត្រួតពិនិត្យក្បាលម្តង ។ សូមខ្វេះយកភ្នែកទាំងមូល ដោយកាត់យកត្រឹមគ្រាប់ភ្នែក និងរង្វង់ភ្នែក ។ ថតរូបទុក រួចហើយត្រាំគ្រាប់ភ្នែកក្នុងទឹកហ្វ័រម៉ាលីន ។

ចុងក្រោយ សូមត្រួតពិនិត្យ និងយកសំណាកពីខួរក្បាល ។ សូមកាត់ក្បាលចេញត្រឹមសន្លាក់ដែលភ្ជាប់ក និងលលាដ៍ក្បាល ។ នៅពេលកាត់ក្បាលបានហើយ សូមបកស្បែក និងព្រលាត់សាច់ចេញឲ្យដល់ឆ្អឹងលលាដ៍ក្បាល ។
ពុះលលាដ៍ក្បាលដោយប្រដាប់កាត់ឆ្អឹង ពូថៅ ឬរណា ទៅតាមទំហំនៃក្បាលសត្វ ។
បើកគម្របលលាដ៍ក្បាលដោយប្រុងប្រយ័ត្នដើម្បីកុំឲ្យប៉ះពាល់ខួរក្បាលវាល ។ សូមថតរូបខួរក្បាលដែលស្ថិតនៅក្នុងលលាដ៍ក្បាលនោះ រួចយកសំណាកដាក់ទៅក្នុងបំពង់ទទេរមួយ ។

សូមយកខួរចេញដោយកាត់សរសៃ និងកោសិកានានាដែលភ្ជាប់វាទៅនឹងលលាដ៍ក្បាល ។ ថតរូបខួរក្បាលតាំងពីលើរហូតដល់ក្រោម ។

ក្រពេញប្រតិកម្ម (Pituitary Gland) ស្ថិតនៅពីក្រោមចំកណ្តាលនៃលលាដ៍ក្បាលពីក្រោមសំណុំខួរតែម្តង ។ សូមកាត់យកវាទុកជាសំណាកត្រាំក្នុងទឹកហ្វ័រម៉ាលីន ។ បើសង្ស័យមានថ្នាំពុល សូមប្រកខួរក្បាលប្រហែល ៥ ទៅ១០ក្រាម ទៅក្នុងថង់ផ្លាស្ទីក ។ ត្រាំចំណែកផ្សេងៗនៃខួរក្បាល ឬសំណុំខួរក្បាលទាំងមូលបើមានទំហំតូចនៅក្នុងទឹកហ្វ័រម៉ាលីន ។

**ចំណុចត្រួតពិនិត្យ ទី៦៖**

មកដល់ចំណុចនេះ អ្នកគួរមានដូចខាងក្រោម៖

- រូបថតភ្នែក និងខួរក្បាល
- រូបថត និងការកត់ត្រាអំពីភាពមិនប្រក្រតីនានាដែលបានជួបប្រទះ
- សំណាកពីភ្នែក ខួរក្បាល និងក្រពេញប្រតិកម្ម

ពេលនេះអ្នកបានបញ្ចប់ការងារប្រមូលសំណាកហើយ!

ត្រូវឲ្យប្រាកដថាទាំងកំណត់ត្រា និងសំណាកទាំងអស់ត្រូវបានសរសេរស្លាកយ៉ាងច្បាស់ និងបិតជាប់ល្អ ។

សូមសម្អាតកន្លែងធ្វើការរបស់អ្នក រួចកំទេចសាកសពសត្វ និងសម្ភារៈវះកាត់ឲ្យបានត្រឹមត្រូវ ។

សូមសម្អាតឧបករណ៍ និងប្រដាប់ប្រដារទុកដាក់សំណាកនានាឲ្យបានហ្មត់ចត់ ។ រក្សាទុកសំណាកក្នុងទូរទឹកកក ឬក្លាសេទឹកកក ឬដាក់ក្នុងធុងទឹកកកយ៉ាងត្រឹមត្រូវ រួចបញ្ជូនសំណាកទាំងនោះសម្រាប់ធ្វើតេស្តដើម្បីធ្វើរោគវិនិច្ឆ័យឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ។ សូមចងចាំថា ត្រូវភ្ជាប់មកជាមួយនូវបញ្ជីផ្ទៀងផ្ទាត់សំណាក រូបថត និងទម្រង់នានាដែលបានបំពេញ ។

សូមអរគុណដែលលោកអ្នកបានជួយតាមដានត្រួតពិនិត្យជម្ងឺសត្វព្រៃ ។ សាកសពសត្វនីមួយៗសុទ្ធតែមានតម្លៃ!